**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# នៃកិច្ចប្រជុំថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅថ្ងៃទី០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ វេលាម៉ោង ០៣:០០ នាទីរសៀល នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមួយ ក្រោមអធិបតីភាព ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

សមាសភាពចូលរួម ក្នុងកិច្ចប្រជុំនេះមាន ៖ ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សា ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តម លោក លោកស្រី ជាអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋានទាំងអស់សរុបចំនួន ២០ នាក់ ។

**អវត្តមាន**

| | | |
|---|---|---|
| ១-ឯកឧត្តមវេជ្ជ. | ជា សំអាន | អនុប្រធានអ.ជ.ប.ជ.អ |
| ២-ឯកឧត្តម | ស៊ឹម គីមសែន | អនុប្រធាន អ.ជ.ប.ជ.អ ( ច្បាប់ ) |
| ៣-ឯកឧត្តមវេជ្ជ. | អ៊ឹង រុទ្ធី | អនុប្រធានអ.ជ.ប.ជ.អ |
| ៤-ឯកឧត្តម | ស៊ឹម គីមសាន | ប្រធាននាយកដ្ឋាន CRM ( ច្បាប់ ) |

គោលបំណងនៃកិច្ចប្រជុំនេះមាន ៖

- របាយការណ៍វឌ្ឍនភាពប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន
- របាយការណ៍ការអនុវត្តកម្មវិធីមូលនិធិសកល
- សេចក្តីផ្សេងៗ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី មានប្រសាសន៍ស្វាគមន៍ ដោយសំដែងការកោតសរសើរ និង អរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីដែលបានចូលរួម ។

## ១- របាយការណ៍វឌ្ឍនភាពប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន (ដោយឯកឧត្តម អគ្គលេខាធិការ ) ៖

### ១.១-ការងាររបស់អគ្គលេខាធិការដ្ឋាន

- កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសស្តីពីការងារទាក់ទងទៅនឹងបញ្ហានៅខេត្តបាត់ដំបងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ។

- ចូលរួមប្រជុំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ។
- សម្របសម្រួលការងារយុវជនសម្រាប់ទិវានៃក្តីស្រលាញ់ ។
- ការគ្រប់គ្រងក្នុងអគ្គលេខាធិការដ្ឋាន ។

១.២-ការងារនាយកដ្ឋាន

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (AFD)

នៅក្នុងខែ មករា ឆ្នាំ២០១៥នេះ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានអនុវត្ត និង សម្រេចការងារមួយចំនួន ដូចខាងក្រោម ៖

ការងារថវិកាជាតិ

- រៀបចំរបាយការណ៍ចំណូល ចំណាយថវិកាជាតិ និង ថវិកាជំនួយឆ្នាំ ២០១៤ ។
- កែតម្រូវផែនការថវិកាឆ្នាំ២០១៥ តម្រូវទៅតាមផែនការថវិកា ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល ។
- រៀបចំជុំរជ្ជទេយ្យដើម្បីស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- រៀបចំបែងចែកសម្ភារៈប្រចាំត្រីមាសជូនថ្នាក់ដឹកនាំ និង គ្រប់នាយកដ្ឋាន ។

ការងារថវិកាជំនួយ

- ពិនិត្យឡើងវិញទៅលើថវិកាមូលនិធិសកល ទៅតាមតម្រូវការរបស់ PR-NCHADS ។
- ចូលរួមកិច្ចប្រជុំជាមួយ NCHADS ស្តីពីទម្រង់របាយការណ៍ថ្មីនៃ PUDR ។
- រៀបចំកិច្ចសន្យាសម្រាប់ ទីប្រឹក្សាបច្ចេកទេស អន្តរជាតិ សម្រាប់ធ្វើការងារ NSP IV ។
- រៀបចំគណនាថវិកាដែលនៅសល់សម្រាប់ មន្ត្រីកិច្ចសន្យា ( TAs ) ។
- រៀបចំរបាយការណ៍ ថវិកាប្រចាំឆ្នាំ ២០១៤ ។
- ធ្វើការទូទាត់ចំណាយប្រចាំថ្ងៃ និង របាយការណ៍ចំណាយទៅតាមតម្រូវការក្នុងការងារគ្រប់គ្រងគម្រោង ។

ការងាររដ្ឋបាល និង បុគ្គលិក

- ប្រមូលឯកសារឆ្នាំ ២០១៤ រក្សាទុក និង បង្កើត File ថ្មីសម្រាប់ឆ្នាំ ២០១៥ ។
- រៀបចំឯកសារស្នើសុំបុគ្គលិកជាប់កិច្ចសន្យា និង អណ្តែត ទៅក្រសួងសុខាភិបាលសម្រាប់ឆ្នាំ ២០១៥ ។
- បានទទួលលិខិតចូលចំនួន ២៥ ។
- បានបញ្ជូនលិខិតចេញ ១៨ ។
- បានរៀបចំលិខិតបេសកកម្ម ជូនថ្នាក់ដឹកនាំ មន្ត្រី ចំណាយថវិកាជាតិចំនួន ១ ។

- បានរៀបចំលិខិតអញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំ និង កិច្ចប្រជុំបច្ចេកទេស ១១ លើក ។
- បានរៀបចំបន្ទប់ប្រជុំសម្រាប់កិច្ចប្រជុំចំនួន ០៥ លើក ។

**នាយកដ្ឋានទាក់ទង និង ចលនាប្រភពធនធាន (CRMD)**

នៅក្នុងខែ មករា ឆ្នាំ២០១៥នេះ នាយកដ្ឋានទាក់ទង និង ចលនាប្រភពធនធាន បានអនុវត្ត និង សម្រេចការងារមួយចំនួន ដូចខាងក្រោម ៖

- ចូលរួមប្រជុំបច្ចេកទេសចំនួន ០៤ លើក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រៃវែង ។
- ចុះវិភាគស្ថានភាពមេរោគអេដស៍ និង ជំងឺអេដស៍នៅខេត្តព្រៃវែង ដើម្បីរកព័ត៌មានសម្រាប់រៀបចំគម្រោងផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ។
- ចូលរួមប្រជុំក្រុមស្នូល និង សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការធ្វើពង្រាងគម្រោងផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ។
- ធ្វើគម្រោងផែនការសកម្មភាពប្រចាំឆ្នាំ ២០១៥ របស់នាយកដ្ឋាន ។

**នាយកដ្ឋានបង្ការ ថែទាំ និង គាំទ្រ (PCSD)**

នៅក្នុងខែ មករា ឆ្នាំ២០១៥នេះ នាយកដ្ឋានបង្ការ ថែទាំ និង គាំទ្រ បានអនុវត្ត និង សម្រេចការងារមួយចំនួន ដូចខាងក្រោម ៖

- រៀបចំគម្រោងផែនការសកម្មភាពរបស់នាយកដ្ឋានសម្រាប់ឆ្នាំ២០១៥ ។
- ជួយដល់ក្រសួងសង្គមកិច្ចក្នុងការរៀបចំកម្មវិធីសម្រាប់ចុះអប់រំដល់កុមារដែលងាយរងគ្រោះដោយសារមេរោគអេដស៍ និង ជំងឺអេដស៍នៅខេត្តកណ្តាល ។
- ចូលរួមសម្របសម្រួលក្នុងសិក្ខាសាលាស្តីពីការធ្វើបច្ចុប្បន្នភាពស្ថានភាព និង ការឆ្លើយតបនិង មេរោគអេដស៍ និង ជំងឺអេដស៍ សម្រាប់បញ្ចូនទៅក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី០៤ ( ២០១៦-២០២០ ) នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៥ នៅភោជនីយដ្ឋានទន្លេបាសាក់ ០២ ។
- ចុះពិនិត្យស្ថានភាពមេរោគអេដស៍ និង ជំងឺអេដស៍ ដើម្បីដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី០៤ នៅខេត្តព្រៃវែង ពីថ្ងៃទី ០៤-០៦ ខែ មករា ឆ្នាំ ២០១៥ ។
- ចូលរួមប្រជុំក្រុមបច្ចេកទេសថ្នាក់ជាតិដើម្បីលើកផែនការយុទ្ធសាស្ត្រជាតិលើកទី០៤ ( ២០១៦-២០២០ ) ។

**នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ(PMERD)**

នៅក្នុងខែ មករា ឆ្នាំ២០១៥នេះ នាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ បានអនុវត្ត និង សម្រេចការងារមួយចំនួន ដូចខាងក្រោម ៖

១-ការរៀបចំរបាយការណ៍វឌ្ឍនភាពទូលំទូលាយ និង ពហុវិស័យ ឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៤

- បានបញ្ចប់របាយការណ៍វឌ្ឍនភាពទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ប្រចាំត្រីមាសទី០៣ ឆ្នាំ ២០១៤ ។ នៅក្នុងត្រីមាសនេះ យើងទទួលបានរបាយការណ៍ចំនួន ២៣ ( ១៤ ខេត្ត និង ៩ ក្រសួង ) ពីស្ថាប័នរាជរដ្ឋាភិបាល និង ចំនួន ០១ ពីអង្គការសង្គមស៊ីវិល ។

២-ការរៀបចំគម្រោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ឆ្នាំ២០១៦-២០២០ (NSPIV)

- កិច្ចប្រជុំក្រុការងារស្នូល ចំនួន០២លើក ដើម្បីពិនិត្យ និង ផ្តល់ទៅលើ
  - ដំណើរការ និង ផែនការលម្អិតនៃការរៀបចំ NSP IV
  - សេចក្តីព្រៀង SRA
  - អនុសាសន៍សម្រាប់ NSP IV
- ចុះសម្របសម្រួលព័ត៌មាននៅតាមថ្នាក់ខេត្ត ( BTB, PVH, PVG, KTM )
- កិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេស ( Prevention, Care and Treatment, Impact Mitigation, Enabling and Environment and M&E ) ដើម្បីរៀបចំធ្វើ SRA
- សិក្ខាសាលាថ្នាក់ជាតិ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៥ ( Validate SRA and Recommendation for NSP IV )
- កិច្ចប្រជុំជាមួយ KAPs និង ថ្នាក់ខេត្ត ដើម្បីពិភាក្សាទៅលើយុទ្ធសាស្ត្រ កម្មវត្ថុ និង សកម្មភាព NSP IV
- សិក្ខាសាលា ពិភាក្សាបន្ថែមទៅលើ NSP IV - Logframe

៣-ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រយុទ្ធនឹងជំងឺអេដស៍នៅប្រទេសកម្ពុជា (GARPR) សម្រាប់ផ្ញើជូនអង្គការសហប្រជាជាតិ

- នាយកដ្ឋានបានទទួល Email ក្នុងការរៀបចំ GARPR ២០១៥ ដែលត្រូវបញ្ជូនរបាយការណ៍នៅថ្ងៃទី៣១ ខែ មិនា ឆ្នាំ ២០១៥ ។
- បានរៀបចំលិខិតទៅ PR-NCHADS ទាក់ទងនឹងការជ្រើសរើស TA សម្រាប់រៀបចំរបាយការណ៍នេះ ។
- រៀបចំផែនការលម្អិត សម្រាប់ការងារនេះ ។

៤- ការផ្តត់ផ្គង់ជំនាញ IT និង ការរៀបចំគេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- Upload ឯកសារសកម្មភាពថ្នាក់ដឹកនាំ កិច្ចប្រជុំ របាយការណ៍ និង សុន្ទរកថាមួយចំនួន ចូលទៅក្នុងគេហទំព័រ
- រៀបចំជាYou Tube Video Clips មួយចំនួលដែលជាសកម្មភាពថ្នាក់ដឹកនាំ និង កិច្ចប្រជុំ ផ្សេងៗទៅក្នុងគេហទំព័រ
- ផ្តល់នូវជំនួយការបច្ចេកទេស IT និង ជួលជុលកុំព្យូទ័រទៅដល់មន្ត្រី

៥-គម្រោងមូលនិធិសកលជំហានទី២

- ធ្វើរបាយការណ៍វឌ្ឍនភាព សំរាប់ការអនុវត្តន៍សម្កោធរបស់គម្រោងមូលនិធិសកល PUDR 8 និងបញ្ជូនទៅ PR-NCHADS និង រង់ចាំការចូលរួមប្រជុំប្រចាំត្រីមាសជាមួយ PR ។
- រៀបចំធ្វើតម្រូវការថវិកាលម្អិតសម្រាប់សកម្មភាពដែលបានយកមកពី (Garry Forward ) ឆ្នាំ ២០១៤ មកប្រើប្រាស់ក្នុងឆ្នាំ ២០១៥ ដល់ខែ មិថុនា ទាំងអស់មាន ១១ កូដ គឺសម្រាប់ធ្វើផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ធ្វើGARPR និង សម្ភារៈការិយាល័យ ។
- ចូលរួមកិច្ចប្រជុំ គណៈកម្មាការគ្រប់គ្រងអនុវត្តន៍ ថវិកាគម្រោង ។ អង្គប្រជុំបានពិនិត្យលើកិច្ចការមួយចំនួនដែលចាំបាច់ត្រូវធ្វើមានដូចជា ការកាត់បន្ថយថវិកាមូលនិធិសកលក្នុងរង្វង់ដែលកំណត់ដោយមូលនិធិសកលគឺដោយបញ្ចូលថវិកា TA IT អ្នកបើកបរទាំង ០៤ TA finance ០២ នាក់ និង TA M&E ។
- បាននឹងកំពុងរៀបចំ ឯកសារសំណុំសកម្មភាពសំរាប់រៀបចំធ្វើ GARPR ប្រចាំឆ្នាំ ២០១៥ ។ ក្នុងកញ្ចប់សកម្មភាពរួមមាន ការជ្រើសរើសទីប្រឹក្សាបច្ចេកទេសជាតិ សំរាប់ជួយធ្វើរបាយការណ៍ជូនទៅ អង្គការសហប្រជាជាតិ ការិយាល័យកម្មវិធីអេដស៍នៅទៅក្រុងហ្សឺណែវ ឱ្យបានមុនថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០១៥ ។

៦-ការរៀបចំរបាយការណ៍ផ្សេងៗ

- របាយការណ៍កិច្ចប្រជុំប្រចាំសប្តាហ៍ របស់នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និង ស្រាវជ្រាវ ចំនួន ០២ ដង ។
- របាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន ០៣ដង ។
- របាយការណ៍ប្រចាំខែ ធ្នូ ឆ្នាំ២០១៤ និង ខែ មករា ឆ្នាំ ២០១៥ របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

- របាយការណ៍សកម្មភាពផ្សេងៗ ដែលនាយកដ្ឋានបានចូលរួម ជាមួយស្ថាប័នដទៃទៀត ។

៧-ការចូលរួមសកម្មភាពផ្សេងៗ

- ចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាជាតិដើម្បីស្ត្រីដើម្បីពិនិត្យទៅលើរបាយការណ៍តាមអនុសាសន៍និងផែនការសម្រាប់ឆ្នាំ ២០១៥ ។
- ចូលរួមជាមួយក្រុមការងារយេនឌ័រទៅក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និង ជំងឺអេដស៍ ដើម្បីបញ្ជូនទៅក្នុង NSP IV ។
- រៀបចំរបាយការណ៍ត្រីមាសទៅUN Women ។
- ចូលរួមប្រជុំប្រចាំត្រីមាស ជាមួយ UN Women ។

២- របាយការណ៍ការអនុវត្តកម្មវិធីមូលនិធិសាកល ( ឯកឧត្តមវេជ្ជ. ទា ផលា )

- បានរៀបចំរបាយការណ៍ នៃការប្រមូលទិន្នន័យ ដើម្បីបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ។
- បានរាយការណ៍ពីដំណើរការនៃកិច្ចប្រជុំការងារអេដស៍នៅប្រទេសថៃ កាលពីថ្ងៃទី ២៩-៣០ ខែ មករា ឆ្នាំ ២០១៥ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី មានអនុសាសន៍

1. អបអរសាទរចំពោះសមិទ្ធផលដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបានក្នុងរយៈពេលកន្លងមក ទាំងអគ្គលេខាធិការដ្ឋាន រួមទាំងនាយកដ្ឋានទាំងអស់ ។
2. សម្តែងការកោតសរសើរចំពោះមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលបានយកចិត្តទុកដាក់បំពេញភារកិច្ចដោយយកចិត្តទុកដាក់ ក្នុងវិន័យ ឯកភាព និង សាមគ្គីភាព ។
3. ណែនាំមន្ត្រីរាជការទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ឲ្យបន្តយកចិត្តទុកដាក់បំពេញភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព វិន័យ និអ សាមគ្គីភាពតទៅទៀត ។
4. ណែនាំឲ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ក្រសួងសុខាភិបាលឲ្យបន្តសហការគ្នាល្អតទៅទៀត ដូចជាចែករំលែកព័ត៌មាន ឬ ទិន្នន័យដែលមាន ឬ ដែលទទួលបានពីមូលដ្ឋាន ឧទាហរណ៍: ករណីឆ្លងមេរោគអេដស៍នៅឃុំរកា ស្រុក សង្កែ ខេត្តបាត់ដំបង ។
5. ណែនាំឲ្យមានការចុះទៅមូលដ្ឋាន ដើម្បីស្វែងយល់អំពីសភាពការណ៍នៃការប្រយុទ្ធនឹងជំងឺអេដស៍ និង អំពីកិច្ចសហការរវាងអង្គភាព ឬស្ថាប័នពាក់ព័ន្ធ ។

6. ណែនាំឲ្យត្រៀមរៀបចំប្រជុំ ក្រុមប្រឹក្សាគោលនយោបាយលើកទី១ ឲ្យបានត្រឹមត្រីមាសទី១ ឆ្នាំ ២០១៥ ។ (ត្រៀមឯកសារពាក់ព័ន្ធ ) ។

7. ណែនាំឲ្យឯកឧត្តមវេជ្ជ. ទា ផលា ធ្វើបច្ចុប្បន្នភាពឯកសារទាំងឡាយដែលបានកំណត់កាលពីសន្និបាតប្រចាំឆ្នាំ ២០១៤ ។

8. ណែនាំនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ពិនិត្យខ្ទង់ចំណាយថវិកាជាតិ ដែលត្រូវសុំកែសម្រួលធ្វើនិយ័តភាព ដើម្បីឲ្យអាចប្រើប្រាស់បានត្រឹមត្រូវ ។

9. ណែនាំឲ្យអគ្គលេខាធិការដ្ឋានពិនិត្យឡើងវិញ នូវឯកសារបទដ្ឋានទាក់ទងនឹងការអនុវត្តន៍ច្បាប់ ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ។

10. ណែនាំឲ្យនាយកដ្ឋាននីមួយៗធ្វើបច្ចុប្បន្នភាពឯកសារដែលត្រូវផ្សព្វផ្សាយតាមwebsite ។

ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៥

**អគ្គលេខាធិការ**

**ឯកឧត្តមវេជ្ជ តែង គន្ធី**

10-2-15